# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

ស្តីពីការព្យួរកិច្ចសន្យាការងាររវាង **តំណាងកម្មករនិយោជិត និងសណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និងស្ប៉ា** កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង១៤ និង ០០នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារនៅក្នុងសណ្ឋាគារ អង្គរ មិរ៉ាខល រីហ្សត និងស្ប៉ា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៦ ភូមិកសិកម្ម សង្កាត់ស្រងែ ស្រុកសៀមរាប ខេត្តសៀមរាប។

**<u>សមាសភាពដែលចូលរួមក្នុងអង្គប្រជុំមាន៖</u>**

| **ក/ភាគីនិយោជក (តំណាងអោយក្រុមហ៊ុន)៖** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| ឈ្មោះ សាន្ត ពិសិត | ប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស | 087 884 433 |

| **ខ/ភាគីកម្មករនិយោជិត (តំណាងអោយកម្មករ)** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| ឈ្មោះ ឆេម ឌីម | ប្រតិភូបុគ្គលិក | 016 601 004 |
| ឈ្មោះ យ៉ាន ចរិយ៉ាផានិត | ផ្នែកហិរញ្ញវត្ថុ | 010 227 397 |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារ សមស្របតាមសេចក្តីណែនាំលេខ: ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់ភាគីទាំងសងខាងបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទាំងអស់ ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ដោយទទួលបានប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ដុល្លាអាមេរិកក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ ដោយឡែក សម្រាប់សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និងស្ប៉ា ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមដល់បុគ្គលិកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារខាងសណ្ឋាគារទទួលរងផលប៉ះពាល់ខ្លាំងពីជម្ងឺ Covid-19 និងបានបាត់បង់ប្រាក់ចំណូល។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១៥ និង ៣០នាទី នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ដោយមានចុះ ហត្ថលេខាព្រមព្រៀងពីតំណាងទាំងដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីទាំងសងខាងដោយបានចុះហត្ថលេខាដូចខាងក្រោម៖

| **ភាគីតំណាងឱ្យនិយោជក** | **ភាគីតំណាងឱ្យកម្មករនិយោជិត** |
|---|---|
| **ហត្ថលេខា/ស្នាមមេដៃ** | **ហត្ថលេខា/ស្នាមមេដៃ** |
| សាន្ត | ឆេម ឌីម |
| | យ៉ាន ចរិយ៉ាផានិត |